**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

លេខ:......................អ.ជ.ប.ជ.អ

# សេចក្តីប្រកាសព័ត៌មាន

គណៈប្រតិភូនៃព្រះរាជាណាចក្រកម្ពុជាដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចេញដំណើរនៅល្ងាចថ្ងៃ២៣ ខែមិថុនា ទៅចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលកម្មវិធីរបស់អង្គការយូអិនអេដស៍ (UNAIDS PCB) លើកទី៥៤ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ដែលប្រព្រឹត្តទៅពីថ្ងៃ២៥ដល់២៧ ខែមិថុនា ឆ្នាំ២០២៤។

ព្រះរាជាណាចក្រកម្ពុជាបានទទួលអាសនៈសមាជិកក្រុមប្រឹក្សាសម្របសម្រួលកម្មវិធីរបស់អង្គការយូអិនអេដស៍ (UNAIDS PCB) តាមរយៈការបោះឆ្នោតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម (ECOSOC) របស់អង្គការសហប្រជាជាតិនៅទីក្រុងញ៉ូវយ៉ក កាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣ តំណាងតំបន់អាស៊ីប៉ាស៊ីហ្វិកសម្រាប់អាណត្តិ២០២៣-២០២៥។ ការចូលរួមប្រជុំរបស់គណៈប្រតិភូកម្ពុជាលើកនេះ ជាការចូលរួមលើកទី៣។

ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងថ្លែងជម្រាបអង្គប្រជុំអំពីវឌ្ឍនភាពនៃការឆ្លើយតបនឹងជំងឺអេដស៍នៅកម្ពុជា ជាពិសេសអំពីការអនុម័តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ដោយកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤កន្លងទៅ។ គោលនយោបាយនេះមានគោលបំណងកាត់បន្ថយការឆ្លងថ្មីឱ្យបានក្រោមមួយនាក់ក្នុងមួយថ្ងៃ ឬក្នុងរង្វង់២០០នាក់ក្នុងមួយឆ្នាំ និងកាត់បន្ថយការស្លាប់ដោយសារអេដស៍ឱ្យនៅក្រោម២០០នាក់ក្នុងមួយឆ្នាំ។

ចីរភាពនៃការឆ្លើយតបនឹងជំងឺអេដស៍នៅកម្ពុជាឈរយ៉ាងរឹងមាំលើសសរស្តម្ភ៣គឺ៖ ១- ភាពជាម្ចាស់ ឬភាពជាអ្នកដឹកនាំ ២- ភាពជាដៃគូពហុវិស័យ និង៣-ការវិនិយោគនៅគ្រប់លំដាប់ថ្នាក់។ គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍បញ្ជាក់ពីតួនាទីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការស្វែងរកធនធានសមស្រប ដើម្បីយកទៅអនុវត្តកម្មវិធីអេដស៍ប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏មានភារកិច្ចវាយតម្លៃអំពីតម្រូវការចាំបាច់នៃការប្រើប្រាស់សេវាឆ្លើយតបនឹងមេរោគអេដស៍ ដោយសង្គមស៊ីវិល ឬអង្គការក្រៅរដ្ឋាភិបាលផងដែរ។ បន្ថែមលើការព្យាបាលអ្នកផ្ទុកមេរោគអេដស៍ដោយឥតគិតថ្លៃ គោលនយោបាយជាតិក៏បានលើកអំពី



អាសយដ្ឋាន: អគារលេខ១៦ ផ្លូវលេខ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក ទូរស័ព្ទ (855) 23 885 109 និង 023 885 129
Tel: (855) 23 885 109 / 023 885 129 E-mail: info@naaa.gov.kh Website: naaa.gov.kh

ការផ្តល់អត្ថប្រយោជន៍នៃកម្មវិធីគាំពារសង្គមដល់អ្នកផ្ទុកមេរោគអេដស៍ និងដល់ប្រជាជនគន្លឹះទៅតាមស្ថានភាពនៃជីវភាពជាក់ស្តែង។

នៅឆ្នាំ២០២២ លើគោលដៅ៩៥-៩៥-៩៥ កម្ពុជាសម្រេចបាន៨៦-៩៩-៩៨ បានន័យថាកម្ពុជាបានសម្រេចគោលដៅពីរួចជាស្រេចលើគោលដៅបី។ ទោះជាចំនួនអ្នកឆ្លងថ្មី និងស្លាប់ដោយសារអេដស៍នៅខ្ពស់នៅឡើយក៏ដោយ (នៅឆ្នាំ២០២២ អ្នកឆ្លងថ្មីមានចំនួន១៤០០នាក់ និងអ្នកស្លាប់ដោយសារអេដស៍មានចំនួន១១០០នាក់) ក៏កម្ពុជាត្រូវបានទទួលស្គាល់ថាឈរលំដាប់កំពូលនៅក្នុងពិភពលោកក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ គឺលេខ១១ លើ១៩៦។

ថ្ងៃចន្ទ ៣រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**